ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន
ពន្យល់ប្រជានបេសកកម្មការទូតអំពីការឃាត់ខ្លួនលោក កឹម សុខា

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានរៀបរាប់ពន្យល់ឯកអគ្គរាជទូត-រដ្ឋទូត/ការៈធារីស្តីទី និងសេនានុពន្ធយោធា នៃបេសកកម្មការទូតទាំងអស់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី០៣ ខែកញ្ញាឆ្នាំ២០១៧ នៅវេលាម៉ោង១០:០០ ព្រឹក អំពីការឃាត់ខ្លួន លោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិ។

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន បានថ្លែងអំណរគុណប្រធានបេសកកម្មការទូតទាំងអស់ ដែលបានឆ្លើយតបចំពោះការអញ្ជើញរបស់ឯកឧត្តម ចូលរួមក្នុងកិច្ចប្រជុំដ៏សំខាន់នេះ ទោះបីជាការជូនដំណឹងក្នុងរយៈពេលខ្លីក៏ដោយ។

បន្ទាប់ពីបានលើកឡើងថា លោក កឹម សុខា ត្រូវបាននគរបាលយុត្តិធម៌ឃាត់ខ្លួន ដោយមានវត្តមានរបស់ព្រះរាជអាជ្ញា នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០១៧ វេលាម៉ោង០០:៣៥នាទីរំលងអាធ្រាត **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានចាប់ផ្តើមការពន្យល់ដោយការចាក់បញ្ចាំងវីដេអូឃ្លីបរបស់លោក កឹម សុខា និយាយអំពីយុទ្ធសាស្ត្រដើម្បីផ្តួលរំលំរដ្ឋាភិបាលបច្ចុប្បន្ន ដែលផលិតដោយ "បណ្តាញផ្សព្វផ្សាយកម្ពុជា" (CBN) មានមូលដ្ឋាននៅប្រទេសអូស្ត្រាលី និងដែលបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ នៅថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១៧។

នៅក្នុងការបកស្រាយពន្យល់ដោយលម្អិត បន្ទាប់ពីការចាក់បញ្ចាំងវីដេអូឃ្លីបនេះរួចមក **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានសង្កត់ធ្ងន់ថា "យុទ្ធសាស្ត្រក្នុងការដណ្តើមអំណាចគឺមានជាទូទៅសម្រាប់គ្រប់គណបក្សនយោបាយ ហើយនោះមិនមែនជាបទល្មើសឡើយ ប៉ុន្តែអ្វីដែលបង្កើតជាបទល្មើស គឺ**របៀបដែលយុទ្ធសាស្ត្រត្រូវបានបង្កើតឡើង** និងថា**អ្នកណានៅពីក្រោយយុទ្ធសាស្ត្រនោះ**" ហើយឯកឧត្តមក៏បានលើកឡើងពីតថភាពនិងមូលដ្ឋានច្បាប់ពាក់ព័ន្ធនឹងការឃាត់ខ្លួនលោក កឹម សុខា ដូចខាងក្រោម៖

- ឃ្លីបវីដេអូ បានបង្ហាញឲ្យឃើញពីសន្និដ្ឋិភាព (ការឃុបឃិតគ្នាជាសម្ងាត់) ដែលលោក កឹម សុខា មានជាមួយបរទេស(មួយឬច្រើន) ដែលបង្កគ្រោះថ្នាក់ដល់កម្ពុជា។

- មាត្រា៤៨៣ នៃក្រមព្រហ្មទណ្ឌរបស់កម្ពុជា ចែងថា៖ "បទសន្និដ្ឋានជាមួយបរទេស គឺជាអំពើត្រូវរ៉ូវគ្នាដោយសម្ងាត់ជាមួយរដ្ឋបរទេស ឬភ្នាក់ងារបរទេស ដើម្បីបង្កើតឲ្យមានអំពើប្រទូស្តរ៉ាយ ឬឲ្យមានអំពើឈ្លានពានប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា។ បទសន្និដ្ឋានជាមួយបរទេស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ) ទៅ៣០ (សាមសិប) ឆ្នាំ។"
- លោក កឹម សុខា បានសារភាពយ៉ាងច្បាស់នៅក្នុងវីដេអូថា សហរដ្ឋអាមេរិក បានប្រាប់លោកតាំងពីដំបូងអំពីអ្វីដែលត្រូវធ្វើ។ គាត់បាននិយាយពីទំនាក់ទំនងរវាងគាត់និងសហរដ្ឋអាមេរិកតាំងពីឆ្នាំ១៩៩៣មក។ គាត់បានដកខ្លួនពីឆាកនយោបាយតាមការណែនាំរបស់ពួកគេ។ គាត់បានយកគំរូតាមប្រទេសយូហ្គោស្លាវី នៅពេលដែលអាមេរិកបានប្រាប់គាត់ឲ្យធ្វើដូច្នេះ។ ទាំងអស់នោះ បានបកស្រាយពីមូលហេតុនៃកូដកម្ម អំពើហឹង្សា និងបាតុកម្ម ... នៅឆ្នាំ២០១៣ និងឆ្នាំ២០១៤។ គាត់ថែមទាំងបាននិយាយថា៖ "គ្មាននរណាម្នាក់ដឹងពីរឿងនេះទេ"។ "ខ្ញុំមិនមែនធ្វើអ្វីដោយចិត្តខ្លួនឯងនោះទេ ខ្ញុំមានអ្នកជំនាញការ និងសាស្ត្រាចារ្យសាកលវិទ្យាល័យនៅរដ្ឋធានីវ៉ាស៊ីនតោន នៅទីក្រុងម៉ុងត្រេអាល់ ប្រទេសកាណាដា ដែលអាមេរិកបានជួលដើម្បីផ្តល់ការណែនាំដល់ខ្ញុំលើយុទ្ធសាស្ត្រផ្លាស់ប្តូរមេដឹកនាំ ..." ។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា "អាជ្ញាធរមានសមត្ថកិច្ច រួមមាននគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញារ ដោយពិនិត្យឃើញថា**វីដេអូឃ្លីបនេះកំពុងបន្តផ្សព្វផ្សាយ** (វីដេអូឃ្លីបនេះ នៅបន្តផ្សព្វផ្សាយរហូតមកដល់ពេលនេះ) និងខ្លឹមសារនៅក្នុងវីដេអូឃ្លីបនេះ **<u>បានឈានដល់ការសន្និដ្ឋានថា នោះគឺជាបទល្មើសជាក់ស្តែង</u>**"។ ឯកឧត្តមបានបន្ថែមថា "ចំពោះបទល្មើសជាក់ស្តែង នគរបាលយុត្តិធម៌<u>អាចចាប់ខ្លួន**ដោយមិនគិតពីអភ័យឯកសិទ្ធិ**</u>សភារបស់បុគ្គលនោះ ពេលវេលា និងទីកន្លែងនៃការចាប់ខ្លួននោះឡើយ" និងថា "ដូចនេះ គាត់នៅមានសិទ្ធិក្នុងការមានមេធាវី និងប្តឹងតវ៉ា"។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់ថា "**អ្វីដែលឯកឧត្តម លោកជំទាវ** បានឃើញនេះ គ្រាន់តែជាភាគខ្លីប៉ុណ្ណោះ។ នៅមានភាគវែងជាងនេះ ដែលបង្ហាញច្រើនជាងនេះ ហើយអាចនឹងបន្ថែមទម្ងន់ដល់ពិរុទ្ធភាពរបស់លោក កឹម សុខា។"

ជាការសន្និដ្ឋាន ឯកឧត្តមទេសរដ្ឋមន្ត្រី បានអះអាងថា "សម្រាប់យើងខ្ញុំ និងសម្រាប់ខ្ញុំផ្ទាល់ នេះគឺ**ជាអំពើក្បត់ជាតិយ៉ាងពិតប្រាកដ**។ ប៉ុន្តែ **សូមទុកឲ្យតុលាការជាអ្នកសម្រេច**។"

ដើម្បីបកស្រាយឲ្យកាន់តែច្បាស់លាស់ថែមទៀត ឯកឧត្តមទេសរដ្ឋមន្ត្រី បាននិយាយយោងទៅដល់ពិធីសច្ចាប្រណិធានចូលកាន់តំណែងរបស់សមាជិកនៃរដ្ឋសភា និងព្រឹទ្ធិសភាទាំងអស់ និងបានអានកហាបណ្ឌគោលនៅក្នុងពាក្យសម្បថដូចតទៅ៖

"ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ**អព្យាក្រឹតភាព**និងភាពមិនចូលបក្សសម្ព័ន្ធសម្រាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឲ្យជនណាមួយក៏ដោយដែលចង់ជ្រៀតជ្រែកចូលក្នុងកិច្ចផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជា ចំពោះគោលនយោបាយជាតិ

និងអន្តរជាតិរបស់កម្ពុជាបានឡើយ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាជាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូចខាតដល់ផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ។"

ឯកឧត្តមទេសរដ្ឋមន្ត្រី បានឆ្លៀតឱកាសនេះ លើកឡើងអំពីលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ហើយនិងបានរំលឹកដល់អង្គទូតទាំងអស់អំពីការគោរពឯករាជ្យ អធិបតេយ្យភាព អព្យាក្រឹត ច្បាប់របស់កម្ពុជា ព្រមទាំងការមិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ដោយសង្កត់ធ្ងន់ថា៖

- "**អង្គការក្រៅរដ្ឋាភិបាល** ត្រូវបានស្វាគមន៍។ អង្គការក្រៅរដ្ឋាភិបាលរាប់រយនិងរាប់ពាន់ បានជួយដល់ប្រទេសរបស់ខ្ញុំ ក្នុងការកសាងកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច អប់រំ វប្បធម៌ សាសនា **លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស** សិទ្ធិក្នុងការបញ្ចេញមតិ និងការអភិវឌ្ឍដទៃផ្សេងទៀត។
- **"តើខ្ញុំគួរលើកឯកឧត្តម លោកជំទាវ អំពីការលះបង់ ដែលយើងបានធ្វើតាំងពីឆ្នាំ១៩៧៩ ក្រោយការរំដោះពីរបប ប៉ុល ពត ដែរទេ?**
- យើងបានកសាងពីគំនរផេះផង់។ យើងបានការពារប្រទេសពីការត្រឡប់មកវិញនៃពួកខ្មែរក្រហម។ យើងបានប្រយុទ្ធប្រឆាំងនឹងពួកខ្មែរក្រហម។ ក្រោមទណ្ឌកម្មសេដ្ឋកិច្ចរយៈពេល១២ឆ្នាំ (ដោយគ្មានជំនួយអភិវឌ្ឍន៍) យើងសម្រេចបានសន្តិភាព និងការបង្រួបបង្រួមជាតិ និងកំណើនផលិតផលក្នុងស្រុកសរុបជាមធ្យមជាង ៧% ក្នុងរយៈពេល២៣ឆ្នាំជាប់ៗគ្នា។
- "តើយើងខ្ញុំចង់បានអ្វីពីប្រទេសទាំងអស់នោះ? ពីឯកឧត្តម លោកជំទាវ? **គឺការគោរពគ្នាទៅវិញទៅមក ការគោរពឯករាជ្យភាព អធិបតេយ្យភាព** និង**អព្យាក្រឹតភាព**របស់យើងខ្ញុំ។ សូមទុកឲ្យប្រជាជនយើងខ្ញុំសម្រេចចិត្តដោយសេរីថាតើអ្នកណាជាអ្នកដឹកនាំពួកគាត់៖ **សូមកុំជ្រៀតជ្រែក និងសូមគោរពច្បាប់របស់យើងខ្ញុំ**។"

ភ្នំពេញ ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៧